# ប្រាសាទអក្សរចារឹក ឬប្រាសាទកាត់ក្ដី

ប្រាសាទនេះមានទីតាំងស្ថិតនៅភូមិតាសែង ឃុំរណសិរ្ស ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ហើយស្ថិតនៅខាងត្បូងធម្មសាលាមួយ ក្នុងបរិវេណកំពែងទី៣ នៃក្រុមប្រាសាទបាកាណ ឬហៅតាមអ្នកស្រាវជ្រាវបារាំងថា "ព្រះខ័ន-កំពង់ស្វាយ"។ ឈ្មោះ "អក្សរចារឹក" គឺជាឈ្មោះដែលអ្នកស្រុកនៅភូមិតាសែងហៅ ដ្បិតគេហៅបែបនេះដោយសារប្រាសាទនេះមានសិលាចារឹកនៅលើមេទ្វារ។ ចំណែក ឈ្មោះមួយទៀតថា "កាត់ក្ដី" គឺជាឈ្មោះដែលយើងឃើញតាមរយៈឯកសារអ្នកស្រាវជ្រាវមួយចំនួន។

ប្រាសាទអក្សរចារឹក សាងសង់ឡើងអំពីថ្មភក់ និងថ្មបាយក្រៀម មានកំពែងព័ទ្ធជុំវិញដែលមានទ្វារចេញចូលគ្រប់ទិសទាំងបួន។ តួប៉មកណ្ដាលរបស់ប្រាសាទនេះ សាងឡើងអំពីថ្មភក់ មានរាងបួនជ្រុងស្មើ ភ្ជាប់ដោយមណ្ឌប និងអន្តរទៅមុខខាងកើតធ្វើអំពីថ្មបាយក្រៀម។ តួប៉មកណ្ដាលមិនមានលម្អជាក្បាច់អ្វីគួរកត់សម្គាល់ឡើយ ពោល គឺមានតែក្បាច់លាតធម្មតានិងរៀបជាទ្វារបញ្ឆោតចំនួនបីប៉ុណ្ណោះ (រូបលេខ១, ២, ៣)។ ទម្រង់ប្លង់របៀបនេះ មានលក្ខណៈដូចទៅនឹងប្រាសាទភ្នំជីសូរ ប្រាសាទគុកនគរ ដែលសុទ្ធសឹងជាសំណង់សាងឡើងក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១០៤៩)។

អ្វីដែលគួរកត់សម្គាល់ នៅប្រាសាទនេះ មានសិលាចារឹកមួយផ្ទាំងដែលគេចុះបញ្ជីលេខ K.161 ចារជាភាសាសំស្ក្រឹត ចំនួន ២០បន្ទាត់ (ផ្នែកខាងលើ ៤បន្ទាត់ជាពាក្យរាយ និង ១៦បន្ទាត់ខាងក្រោមជាពាក្យកាព្យ ស្មើនឹង ៨ ស្លោក)។ នៅឆ្នាំ១៩៦៦ លោក George Coedès បានចុះក្នុងបញ្ជីសៀវភៅវគ្គទី៨របស់លោក តែមិនបានបកប្រែអត្ថន័យទាំងស្រុងនោះឡើយ ពោល គឺគ្រាន់តែបានបញ្ជាក់ថាជាភាសាសំស្ក្រឹត និងមានកាលបរិច្ឆេទនៅម.ស.៩២៤ ត្រូវនឹងគ.ស.១០០២។ មុនការផ្សព្វផ្សាយរបស់លោក George Coedès សិលាចារឹកនេះធ្លាប់បានចុះផ្សាយនៅក្នុងព្រឹត្តិបត្រអាស៊ី (*Journal Asiatique*) កាលពីឆ្នាំ១៨៨៣, ១៨៨៤[១] ហើយក៏ធ្លាប់បានសិក្សាខ្លះៗដោយលោក Etienne Aymonier[២] លោក Lunet De Lajonquière[៣] ។ល។ ក្នុងឆ្នាំ២០១៨ លោក កំ វណ្ណារ៉ា ក៏បានប្រែសិលាចារឹកនេះទាំងស្រុងម្ដងទៀតផង។

---

[១] Journal Asiatique 1883: 256; 1884: 66.

[២] Aymonier 1900: 439-440.

[៣] Lajonquieère 1902: 246.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

**អត្ថបទដើមជាអក្សរខ្មែរជំនើប**

១. ត្រីមតិ ចាជាត្រលីលាវនមិតឯរណីក្សោភសំក្សោភិតាម្ពុំ
ភ្រាម្យត្ត្រិន្ទត្ឫបេន្ទ្រំ កុជវលបវនៃសិ សំស្វូលត្បទ្ធិមានៃះ
ស្វាង្គ័សិ ស្វល្បីក្ម្វតាគំ នវវសរុចិភិរ៑ វិស្ផុរទ្រិត្នីមាល្បៃរ៑
ជាជ្យំ ប្រហ្មាទិសេវ្យំ សុខយតុ ឧយិតានន្ទធំ ចន្ទ្រមៅលេះ។

២. នមោ វុទ្ធាយ សវ៌្វជ្ញ — គភ្ភេ យត្រៃវ សាជ៌កាះ
តស្មៃ ហិ វចសិ សត្យំ — ប្រមាណេន និរុបិតមិ។

៣. តទុត្តោ ចារមិតន្ត្រ — តយោ តន្តតយោតិនះ
ត្រ្យក្សរញ្ញនីជជ្ញានំ — កុរុ ចាន យុតនិ នមេ។

៤. ត្រិទ្ធតិ ត្រិស្វយ៌្យរម្នាំសិច — ចតុភ៌ុជវិសាសកះ
យសិ ស្វយ៌្យវត្តជោ រាជ្យេ — ចតុភ៌ុជវិលាសកះ ។

៥. ស្នរោ នត្តតិ គតាត្តោ — បិ គតីតិ នវវធ្យកាមិ
អស្វជនិ យនិ ឆ្វ ឥនងី — កម្ម៌ កាន្តិសត្កាវជិច្ចយា។

៦. ភាម្យានិចរណា គាវ្យ — ចាណាំមិ មទ្ធត៌នេន្ទ្រិយា
យន្នតិរ៑ ជម៌្មតាស្រ្តានិ- — មស្តកា ជង្គមាយត។

៧. ឯតាវតានុមេយំ យនិ — វិយំ យនិ វ្ឈនិរ៑ មុនិះ
វណោស្មោ រាជសត្តិណ៌ានិ — រាជ្ញោ  រាជ្យំ ជហារ យះ។

៨. កាលនោមានលាវិម្ពា — យស្យ សេកម្មុនិត្តមេ
តទ្ទិជាគាតិ ក្សណំ លោភាះ — សុខាយន្តេ ស្មសវ៌ថ។

៩. យុគហានេរ៑ អយនិ ជម៌្មះ — បទហីនោ ជរាត្មូគះ
យន្និតិរសំ អាសាធ្យ — សត្បទសិ ស្ម យុរាយតេ។

**សេចក្ដីប្រែជាភាសាខ្មែរជំនើប**[4]

*១. ដោយធ្វើឱ្យកក្រើកអស់ស្ថានទាំងឡាយនៅក្នុងលំហ ដោយការរញ្ជួយដែនដីដែលបាក់ស្រុតនៅក្រោមចុងម្រាមនៃព្រះបាទរបស់ទ្រង់, ដោយធ្វើឱ្យផ្អើលអស់ទេវតាទាំងឡាយប្រៀបបានដូចជាសន្ទឹកព្រះឥន្ទ្រ?នៅក្នុងខ្យល់នៃព្រះហស្តដ៏មានអនុភាពដែលធ្វើឱ្យគ្រលែងវិមានអាកាស។ ដោយបង្រួមលំហឱ្យតូចដោយអវយវៈដែលមានពន្លឺនៃញើសថ្មី និងក្រងជាកម្រងនៃការស្មឹគ្នីផ្ទេក។ សូមឱ្យរបាំ នាំមកនូវសុភមង្គលទទួលបានការចាប់អារម្មណ៍ដោយសេចក្ដីគោរពពីពួក*

(4) *ប្រែសម្រួលដោយ កំ វណ្ណារ៉ា ២០១៨: ១៧-១៩។*

*អត្ថបទដោយ៖ ម៉ង់ រ៉ាលី*

ទេវតាទាំងពួងនិងសេចក្ដីត្រេកត្រអាលអនេក ដែលជាបរិវារនៃមហាទេពពាក់មកុដព្រះចន្ទ្រ (ព្រះឥសូរ)។

២. សូមរំឭកដល់គុណព្រះពុទ្ធ, បុគ្គលតែមួយគត់ដែលបានបំពេញដោយអត្ថន័យក្នុងនាមជាសព្វញ្ញូ, ជាបុគ្គលដែលមានវាចាត្រូវ និងបង្កើតឡើងទៅតាមតក្កភាព។

៣. ការបង្ហាត់បង្ហាញដោយទ្រង់ប្រៀបដូចជាទូកចំនួនពីរនៃលទ្ធិបារមីសម្រាប់យោគិនអ្នកប្រតិបត្តិតាម, ខ្ញុំម្ចាស់សូមក្រាបថ្វាយបង្គំ ចំពោះព្រះបាទាទាំងគូរបស់ព្រះបរមគ្រូដែលចំណេះដឹងវិទ្យាសាស្ត្ររបស់ទ្រង់ជាចំណេះដឹង ដែលមានប្រភពចេញពីសេចក្ដីអនុគ្រោះពីព្រះមហាទេវត្រៃនេត្រ។

៤. ព្រះបាទស្រីសូរ្យវម៌្ម ព្រះអង្គបរិបូណ៌ដោយមង្គល ដែលទទួលបានពីការប្រទានពរពីព្រះវិស្ណុ, ទ្រង់បានប្រសូត្រចេញពីត្រកូលសូរ្យវង្ស (វង្សព្រះអាទិត្យ) ដោយនៅក្នុងរជ្ជកាលរបស់ព្រះអង្គ មានគោលការណ៍គ្រឹះ ៤ ព្រះហស្តនិងទឹកព្រះទ័យប្រកបដោយមេត្តាករុណា។

៥. មហាជនទាំងឡាយបានប្រទានព្រះគោរមងារថា ស្នារ, គគាង្គ, គគិន ដ្បិតព្រះអង្គទ្រង់បានបំពេញរាជកិច្ចល្អឥតខ្ចោះ តាមព្រះរាជបំណងប្រាថ្នារបស់ទ្រង់។

៦. ព្រះអង្គមានព្រះបាទជា ភាព្យ មានព្រះហស្តជា កាវ្យ, មានព្រះកាយជា ទស៌ន ទាំង៦ មានព្រះសិរជា ធម្មសាស្ត្រ ប្រាជ្ញារបស់ព្រះអង្គប្រៀបដូចជាមនុស្សមានជីវិត។

៧. ព្រះអង្គទ្រង់មានសេចក្ដីក្លាហានដ៏លើសលប់, ទ្រង់ជាព្រះមុនី ពោលគឺមានចំណេះដឹងទូលំទូលាយ ដែលអ្នកផងទាំងពួងមើលឃើញហើយអាចសន្និដ្ឋានបានតាមរយៈ អ្វីដែលព្រះអង្គទ្រង់បានបង្ហាញនៅលើសមរភូមិ ដើម្បីអាណាចក្ររបស់ទ្រង់ និងដើម្បីក្លាយជាស្ដេចតែមួយព្រះអង្គប្រសើរលើសក្សត្រទាំងពួង។

៨. មនុស្សលោកដែលទទួលបានទារុណកម្មដោយភ្លើងនៃបាបកម្ម ព្រោះអំណាចពេលវេលា, កាលបើភ្លើងនោះរលត់ដោយទឹក ពោលគឺ សេរីភាព ហើយមនុស្សលោកនឹងទទួលបាននូវភាពរីករាយ។

៩. ដោយការបរិបូណ៌នៃយោគៈ, ធម៌ជាកម្មសិទ្ធិនៃព្រះបាទារបស់ទ្រង់ នឹងត្រូវក្រៀមស្វិតស្រពោន ដោយអំណាចជរាភាព ដោយសារទឹកអម្ឫត នៃព្រះរាជកិច្ចរបស់ទ្រង់, ទ្រង់បានរកឃើញដំហរ និងយុវភាពរបស់ទ្រង់។

តាមខ្លឹមសារនៃសិលាចារឹកនេះ អាចឱ្យយើងដឹងច្បាស់ថា ព្រះបាទសូរ្យវរ្ម័នទី១ ទ្រង់គោរពប្រណិប័តន៍ព្រហ្មញ្ញសាសនាផង និងព្រះពុទ្ធសាសនាផង ហើយទ្រង់ជាស្ដេចមួយអង្គ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ដែលមានឫទ្ធានុភាព ដូចការពោលសរសើរនៅក្នុងស្លោកសំស្ក្រឹតខាងលើស្រាប់។ ចំណែក បើយោងទៅលើស្ថាបត្យកម្ម និងសិលាចារឹកនេះ អាចឱ្យយើងដឹងថាប្រាសាទនេះ ទំនងសាងឡើងនៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១០៤៩)។ ប្រាសាទនេះ អាចជាសំណង់ចាស់ជាងគេនៅក្នុងក្រុមបាកាណ ដែលទំនងឧទ្ទិសដល់ព្រហ្មញ្ញសាសនាផង ព្រះពុទ្ធសាសនាផង ហើយក្រោយមកនៅក្នុងរាជ្យស្ដេចបន្តបន្ទាប់គេបានសាងសំណង់បន្ថែម និងបានកែលម្អប្ដូរទៅជាសាសនដ្ឋានព្រះពុទ្ធសាសនាមហាយានដ៏ធំមួយនៅកម្ពុជា។

## ឯកសារយោង


**កំ វណ្ណារ៉ា**

២០១៨, *ប្រជុំសិលាចារឹកខេត្តព្រះវិហារ*, ភ្នំពេញ

**Aymonier, Etienne**

1900, *Le Cambodge: Le Royaum Actuel*. Paris. Ernest Leroux.

**Lunet De Lajonquière**

1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris




រូបលេខ១៖ ប្រាសាទអក្សរចារឹក ឬប្រាសាទកាត់ក្ដី (មើលពីទិសខាងជើង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៖ ប្រាសាទកាត់ក្ដី ឬប្រាសាទអក្សរចារឹក (មើលពីទិសឦសាន)



រូបលេខ៣៖ ប្រាសាទកាត់ក្ដី ឬប្រាសាទអក្សរចារឹក (មើលពីខាងជើង)



រូបលេខ៤៖ ប្រាសាទកាត់ក្ដី ឬប្រាសាទអក្សរចារឹក (មើលពីទិសពាយព្យ)



រូបលេខ៥៖ ប្រាសាទកាត់ក្ដី ឬប្រាសាទអក្សរចារឹក (មើលពីទិសអាគ្នេយ៍)



រូបលេខ២៦៖ ក្រដាសផ្តាមសិលាចារឹកប្រាសាទអក្សរចារឹក (ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយៈ ម៉ង់ វ៉ាលី